អនុក្រឹត្យលេខ ៧០ អនក្រ.បក

ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ

តំបន់ព្រៃកោងកាង នៅខេត្តព្រះសីហនុ

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ ក្រច. ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧

សំរេច

មាត្រា ១.-តំបន់ព្រែកទឹកសាប ជាប្រភពតែមួយគត់សំរាប់ធានានិរន្តភាព នៃការអភិវឌ្ឍន៍ក្រុងព្រះសីហនុ ដែលកំពុងរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយចាំបាច់ត្រូវរៀបចំថែរក្សាការពារអោយមានស្ថេរភាពឡើងវិញ ។

មាត្រា ២.-តំបន់ព្រែកទឹកសាប ជាតំបន់ព្រៃបំរុងទុករបស់រដ្ឋ សំរាប់ផលប្រយោជន៍សាធារណៈ ស្ថិតនៅលើចំណុចប្រសព្វគ្នានៃខ័ណ្ឌមិត្តភាព ស្ទឹងហាវ និងខ័ណ្ឌព្រៃនុប ដូចមានកំណត់ក្នុងផែនទីខ្នាត 1:50.000 ផែនទីឋានលេខាចំណងជើង ក្រុងព្រះសីហនុ ។ លេខសំគាល់ №5.730. III សេរី L7016 ភ្ជាប់មកជាមួយនេះ ។ ទីតាំងនៃតំបន់ព្រែកទឹកសាបនេះមានផ្ទៃដីទំហំ 6.202 ហ.តស្ថិតនៅត្រង់ចន្លោះខ្សែស្របទី 10°30' និង 10° នៃរយៈទទឹងខាងជើង និងខ្សែបណ្តោយទី 103°30' និង 104° នៃរយៈបណ្តោយខាងកើត ។

មាត្រា ៣.- មិនអនុញ្ញាតអោយមានការអភិវឌ្ឍន៍ផ្នែក វារីវប្បកម្ម វិស័យទេសចរណ៍ វិស័យឧស្សាហកម្ម រួមទាំងកសិ-ឧស្សាហកម្ម ដែលជាប្រភពនៃការបំពុលទឹកក្រោមដី និងលើដី ។

មាត្រា ៤.- ចំពោះសកម្មភាពដែលកំពុងដំណើរការបច្ចុប្បន្ន ទាមទារអោយមានការវាយតម្លៃហេតុប៉ះពាល់ពាល់បរិស្ថាន ។

មាត្រា ៥.- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ច :

-ថែរក្សាការពារព្រៃធម្មជាតិ សត្វព្រៃ និង ដាំឈើឡើងវិញ ។

-គ្រប់គ្រងការពារធនធានទឹក ដោយសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

មាត្រា ៦.- រាល់បទបញ្ញត្តិទាំងឡាយផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន